# សុវត្ថិភាពឧស្ម័នប្រូប៉េន

បើអ្នកសង្ស័យថាមានលេចឧស្ម័ន នៅក្នុងផ្ទះសណ្ដោងរបស់អ្នក ចូរកុំរកកន្លែងលេចដោយខ្លួនឯងឲ្យសោះ ។ ត្រូវចាកចេញមួយរំពេច ដោយទុកទ្វារឲ្យនៅចំហចោល ចេញទៅខាងក្រៅ បន្ទាប់មកក៏ទូរស័ព្ទទៅលេខ 911 ឬ ក្រសួងអគ្គីភ័យក្នុងតំបន់របស់អ្នក ដើម្បីរាយការណ៍អំពី ការលេចឧស្ម័ន ។

បើសិនអ្នកសង្ស័យថាមានលេចឧស្ម័ន ចូរកុំប្រើប្រដាប់បើកបញ្ចេះចង្កៀន និងកុំមួលបើក ឬបិទគ្រឿងប្រើប្រាស់អគ្គិសនី ឬកុងតាក់បិទបើកភ្លើង ឲ្យសោះ ។ បើអ្នកអាចធ្វើដោយសុវត្ថិភាពបាន ត្រូវបិទធុងឧស្ម័នប្រូប៉េន និងបិទភ្លើងផ្ទះសណ្ដោងរបស់អ្នក នៅត្រង់បង្គោល ឬនៅមេកុងតាក់បិទបើក រួចចេញពីផ្ទះរបស់អ្នក ក្នុងពេលអ្នកកំពុងរង់ចាំក្រសួងអគ្គីភ័យមកដល់ ។

### ឱវាទសុវត្ថិភាពផ្សេងទៀត សំរាប់ឧស្ម័នប្រូប៉េន

- ត្រូវឲ្យប្រាកដថាមានខ្យល់ចេញចូលគ្រប់គ្រាន់ជានិច្ច នៅក្នុងផ្ទះសណ្ដោងរបស់អ្នក នៅពេលដាំស្ល ។
- ត្រូវរកចំណុចបំពង់ផ្សែងកំដៅនៃធុងឧស្ម័នប្រូប៉េន សំរាប់ផ្ទះសណ្ដោងរបស់អ្នក (**បើមានបញ្ហាក្នុងការរកវា ត្រូវទូរស័ព្ទ** FEMA) ហើយធ្វើឲ្យប្រាកដថាវត្ថុដែលអាចឆាបឆេះទាំងអស់ ដូចជាកន្សែងពោះគោ ឈើ ឬមែកឪស គឺឋិតនៅឆ្ងាយស្រឡះពីវា ។
- នៅពេលអ្នកដូរធុងឧស្ម័នប្រូប៉េន បន្ទាប់ពីបានបំពេញសាថ្មី ត្រូវពិនិត្យរកមើលការលេច ដោយហិតរកកន្លែងមានក្លិនស្អុយដូចមើមខ្ទឹមបារាំង ។ បើអ្នកធុំក្លិនលេច ត្រូវតខ្សែតំណសាថ្មី និងពិនិត្យមើលមុខតំណម្ដងទៀត ហើយទូរស័ព្ទទៅលេខជំនួយផ្ទះសណ្ដោង FEMA (888-294-2822) បើនៅតែមានលេចដដែល ។
- ត្រូវពិនិត្យរកមើលការលេចឧស្ម័នសិន មុននឹងផ្ដាច់ ឬតខ្សែកាបអាគុយ ចេញពីផ្ទះសណ្ដោងរបស់អ្នក ។

**លេខជំនួយផ្ទះសណ្ដោង FEMA គឺ 888-294-2822**

# សន្តិសុខ

- ត្រូវបង្រៀនកូនរបស់អ្នក ថាសត្វព្រៃដើរវង្វេងដែលគេជួបប្រទះនៅក្នុងរមណីយដ្ឋានផ្ទះសណ្ដោង ប្រហែលជាមិនស៊ាំងឡើយ ។ គេគួរតែប្រព្រឹត្តចំពោះសត្វទាំងអស់ដែលឥតចងខ្សែ ថាជាសត្វប្រកបដោយគ្រោះថ្នាក់ ។
- បើអ្នកឃើញសកម្មភាពបទឧក្រិដ្ឋអ្វីកំពុងកើតឡើង នៅក្នុងរមណីយដ្ឋានផ្ទះសណ្ដោងរបស់អ្នក ត្រូវទូរស័ព្ទទៅអាជ្ញាធរនៅក្នុងតំបន់ ដើម្បីរាយការណ៍អំពីរឿងនោះ ទៅបុគ្គលិករក្សាសន្តិសុខដែល FEMA បានចុះកុងត្រា ឬអ្នកចាត់ចែងការរមណីយដ្ឋាន ។ បើអ្នកមិនរាយការណ៍ទេ សកម្មភាពនៃបទឧក្រិដ្ឋ អាចនឹង អាក្រក់ខ្លាំងឡើង ។
- បើមានអាងហែលទឹកនៅក្នុងរមណីយដ្ឋានផ្ទះសណ្ដោង ត្រូវឲ្យប្រាកដថាអ្នកត្រួតមើលកូនរបស់អ្នកយ៉ាងជិតដិត ទាំងបង្រៀនគេថា គេមិនត្រូវទៅលេងនៅអាងហែលទឹក ដោយគ្មានការអនុញ្ញាតពីអ្នកឡើយ ហើយជាដាច់ខាតត្រូវតែមានការត្រួតមើលពីមនុស្សចាស់ ។
- រមណីយដ្ឋានផ្ទះសណ្ដោង មានក្មេងច្រើនលេងនៅជុំវិញ ។ ត្រូវមានទំលាប់ដើរក្រឡឹងជុំវិញពីក្រោយឡានរបស់អ្នក ដើម្បីពិនិត្យមើលក្មេងមុននឹងថយឡានចេញ ។
- ចូរកុំជជែកឈ្លោះជាមួយនឹងអ្នកជិតខាង ឲ្យសោះ ។ បើអ្នកមានទំនាស់គ្នាដែលអ្នកពុំអាចដោះស្រាយដោយសន្តិភាពបានទេ ត្រូវទាក់ទងទៅអាជ្ញាធរ ។
- *ត្រូវរាយការណ៍នូវសកម្មភាពសង្ស័យទាំងអស់ ទៅប៉ូលីសនៅតាមតំបន់ ឬឆ្មាំរក្សាសន្តិសុខនៅតាមក្រុមទីកន្លែងនានា ។*

*បានកែសំរួលនៅថ្ងៃទី 29 ខែកញ្ញា ឆ្នាំ 2006*

FEMA

# ផ្ទះសណ្ដោងធ្វើដំណើរ : ឱវាទសំរាប់សុវត្ថិភាព និងការបង្ការអគ្គីភ័យ



**លេខជំនួយផ្ទះសណ្ដោង FEMA គឺ :**

**888-294-2822**

Cambodian

# សុវត្ថិភាពចង្ក្រាន

- ត្រូវចងចាំថា ប្រដាប់មួលបិទបើកចង្ក្រានផ្ទះសណ្តោង អាចខុសគ្នាពីចង្ក្រានធម្មតា ។ ការរំលឹកមនុស្សទាំងអស់ អំពីរបៀប ប្រើវាយ៉ាងត្រឹមត្រូវ គឺជាសារៈសំខាន់ណាស់ ។ ត្រូវកុំភ្លេច និងសំគាល់មើលប្រដាប់មួលបញ្ឆេះណាមួយ និងប្រដាប់មួលបិទបើករង្វង់កំដៅណាមួយ ។ សូមចំណាំ : FEMA កំពុងតែដូរផ្លាស់ប្រដាប់មួលបញ្ឆេះ ជាមួយនឹងពណ៌ក្រហមមួយ (ដូចរូបភាពនៅខាងក្រោម) ។



- បើរង្វង់កំដៅមិនចាប់ផ្តើមឆេះ បន្ទាប់ពីមួលប្រដាប់បញ្ឆេះពីរបីជុំរួចហើយ ត្រូវរង់ចាំយ៉ាងហោចបំផុតចំនួន 30 វិនាទី ឬធ្វើឲ្យចំហាយខ្យល់ចេញសិន មុននឹងសាកបញ្ឆេះរង្វង់កំដៅម្តងទៀត ។ **ការចងចាំ** : ឧស្ម័នប្រូប៉េននឹងនៅមានលើវានចង្ក្រានជាដដែល បើអ្នកបានបើករង្វង់កំដៅ ប៉ុន្តែវាមិនបានឆេះ ។ បើអ្នកគូសឈើគូសឬព្យាយាមមួលប្រដាប់បញ្ឆេះម្តងហើយម្តងទៀត អាចបណ្តាលឲ្យឧស្ម័ននោះផ្ទុះ ។
- ចូរកុំចំអិនម្ហូបដោយឥតនៅចាំមើល ទោះបើតែពីរបីនាទីក៏ដោយ ។ បើអ្នកត្រូវចេញទៅក្រៅ ត្រូវបិទ រង្វង់កំដៅមុននឹងចាកចេញ ។
- សំរាប់ផ្ទះសណ្តោងដែលមានចង្ក្រានប្រើអគ្គិសនីវិញ បើផ្ទះសណ្តោងរបស់អ្នកដាច់អគ្គិសនី នោះត្រូវនឹកចាំថា រង្វង់កំដៅនៃចង្ក្រានរបស់អ្នកអាចនឹងនៅបើកដដែល ។ បើអ្នកចេញទៅណា ហើយនៅពេលមានអគ្គិសនីវិញ រង្វង់កំដៅនៃចង្ក្រានរបស់អ្នកនឹងចាប់ផ្តើមឆេះ លុះត្រាតែអ្នកបានមួលបិទវា ។

# សុវត្ថិភាពអគ្គីភ័យ

ជារៀងរាល់ឆ្នាំ អគ្គីភ័យបានប្រល័យជីវិតប្រជាជនអាមេរិកាំង 4,000 នាក់ និងមានរបួសប្រហែលជា 25,000 នាក់ ។ ភាគច្រើននៃអគ្គីភ័យទាំងនេះ គឺបានបណ្តាលដោយសារការប្រើប្រាស់មិនត្រឹមត្រូវ ឬថែរក្សាគ្រឿងអគ្គិសនីមិនបានល្អ ដូចជាការប្រើខ្សែ បន្តភ្លើងលើសចំណុះ ឬការប្រើម៉ាស៊ីនកំដៅតូចៗជិតទៅនឹងវត្ថុដែលអាចឆាបឆេះ ដូចជាក្រណាត់ក្រាលគ្រែ តុទូ និងវាំងនន ។

រដ្ឋ ខណ្ឌ ទីក្រុង របស់អ្នក និងអ្នកស៊ើបអង្កេតអគ្គីភ័យដោយស្ម័គ្រចិត្ត ចង់ឲ្យអ្នកដឹងថា វាមានវិធានការយ៉ាង ងាយស្រួលដែលអ្នកអាចធ្វើ ដើម្បីការពារកុំឲ្យបាត់បង់ជីវិត និងទ្រព្យសម្បត្តិ បណ្តាលដោយសារអគ្គីភ័យ ចេញពីផ្ទះសណ្តោង ។

- ចូរកុំធ្វើការផ្លាស់ប្តូរជាបណ្តោះអាសន្នទៅលើផ្ទះរបស់ អ្នកឲ្យសោះ លុះត្រាតែ FEMA បានទទួលយល់ព្រម ។ ប្រព័ន្ធឧស្ម័នបានតម្រូវទៅតាមទំហំនៃធុងឧស្ម័នប្រូប៉េន នៅនឹងផ្ទះសណ្តោងរបស់អ្នក ។ បើអ្នកបន្ថែមធុងមួយដែលធំជាង អ្នកអាចធ្វើឲ្យខ្សែបំពង់ឧស្ម័នប្រូប៉េន ហើយនិងប្រដាប់កម្រិតឧស្ម័នលើសចំណុះ ។
- ចូរកុំយកវត្ថុធាតុរាវដែលអាចឆាបឆេះ (ដូចជា សាំង ឬ ប្រេងកាត) ចូលមកក្នុងផ្ទះរបស់អ្នក ឲ្យសោះ ។
- ចូរកុំចងខ្សែអគ្គិសនីផ្អោបទៅនឹងជញ្ជាំង ដាក់នៅពីក្រោមកំរាលព្រំ និងនៅតាមផ្លូវដើរ ឲ្យសោះ ។ ត្រូវ ចងចាំថា ប្រដាប់ដោតអគ្គិសនីនៃផ្ទះសណ្តោងរបស់អ្នក មានកំរិតចំនួនគ្រឿងប្រើប្រាស់អគ្គិសនីម៉្លោះហើយចូរកុំប្រើឲ្យលើសចំណុះរបស់វា ។
- មិនត្រូវជក់បារីនៅក្នុងគ្រែ នៅក្នុងផ្ទះសណ្តោងរបស់អ្នក ឲ្យសោះ ។ បើអ្នកចង់ជក់នៅក្នុងផ្ទះសណ្តោង ត្រូវប្រើចានដាក់កន្ទុយបារីធ្វើពីដែក ឬពីដីដែលជ្រៅ ព្រមទាំងត្រូវធ្វើឲ្យប្រាកដថាបានពន្លត់បារី មុននឹងចោលវាទៅក្នុងចានដាក់កន្ទុយបារី ។
- ត្រូវប្រាកដថាប្រដាប់ស្រូបក្លិនផ្សែងដើរ ហើយសាកមើលវារៀងរាល់ខែ ។ បើវាមិនដើរត្រឹមត្រូវទេ ត្រូវទូរស័ព្ទទៅ FEMA ហើយរាយការណ៍វា ។
- ហើយក៏ មិនត្រូវទុកទៀនឲ្យឆេះចោល ដោយពុំមានមនុស្សនៅក្នុងផ្ទះសណ្តោងឡើយ ។

# គំរោងការសំរាប់គ្រួសារ

- ត្រូវរាប់បញ្ចូលសមាជិកគ្រួសារទាំងអស់ នៅក្នុងការប្រុងប្រៀបរបស់អ្នក ប្រយោជន៍ឲ្យគេទាំងអស់ដឹងអំពីគំរោងការ ។
- ត្រូវសំរេចយកផ្លូវពីរសំរាប់គេចខ្លួន ។ បង្អួចនៅក្នុងផ្ទះសណ្តោងគឺអាចយកចេញបាន ហើយក៏ធំល្មមសំរាប់មនុស្សភាគច្រើនអាចចេញរួច ។ ទាំងធ្វើឲ្យប្រាកដថា បង្អួចអាចចេញចូលបាន និងអាចបើកចំហបាន នៅក្នុងព្រឹត្តិការណ៍ដែលអ្នកត្រូវតែចេញតាមចន្លោះនោះបាន ក្នុងពេលមានអគ្គីភ័យ ។
- ត្រូវពិគ្រោះគ្នា និងយល់ស្របគ្នា ថាត្រូវធ្វើយ៉ាងណាចំពោះសត្វចិញ្ចឹម បើមានអគ្គីភ័យកើតឡើង ។
- ត្រូវកំណត់ទីកន្លែងមួយនៅខាងក្រៅ សំរាប់ឲ្យសមាជិកគ្រួសារទាំងអស់ អាចជួបគ្នានៅពេលបន្ទាប់ពីការរត់គេចអគ្គីភ័យ ។
- បើមានអគ្គីភ័យកើតឡើងនៅក្នុងផ្ទះសណ្តោងរបស់អ្នក ត្រូវរក្សាក្បាលរបស់អ្នកឲ្យផុតពីពិតាន ជាកន្លែងដែលមានកំដៅខ្លាំងជាងគេ ។ ត្រូវនៅឲ្យទាប ហើយរត់ចេញឲ្យលឿនបំផុត ។
- បើអាចធ្វើបាន ត្រូវបិទទ្វារនៅពេលអ្នកចេញ ដើម្បី ជួយបន្ថយខ្យល់អុកហ្ស៊ីសែនទៅដល់អណ្តាតភ្លើង ។
- ត្រូវធ្វើឲ្យប្រាកដថាផ្នែកនៃគំរោងការរបស់អ្នក មានរាប់បញ្ចូលនូវការថែទាំមនុស្សដែលអាចនឹងត្រូវការជំនួយពិសេស ។
- ត្រូវរកកន្លែងដែលឋិតនៅជិតជាងគេបំផុត ដែលអ្នកអាចហៅលេខ 911 ទាំងសន្មតថាទូរស័ព្ទដៃរបស់អ្នក នឹងពុំអាចទូរស័ព្ទទាក់ទងបានទេ ។
- ត្រូវហាត់គំរោងការជំលៀសខ្លួន ជាមួយនឹងសមាជិកគ្រួសារទាំងអស់ រួមទាំងការមើលថែសត្វចិញ្ចឹមដែរ ។

**លេខជំនួយផ្ទះសណ្តោង FEMA គឺ : 888-294-2822**